# ៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និង នេសាទ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ៣៥៩ ប្រក.កសក.ចត**

**ស្តីពីការបង្កើតការិយាល័យអាស៊ាន កសិកម្ម**

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ១៩៩៤ ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម ។
- បានឃើញលិខិតលេខ ២៩៦ សជអាជក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**សំរេច**

**មាត្រា ១ :** បង្កើតការិយាល័យអាស៊ានកសិកម្ម ចំណុះនាយកដ្ឋានផែនការ និង សហប្រតិបត្តិការ នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ២ :** ការិយាល័យអាស៊ានកសិកម្ម មានភារកិច្ច :

- ជាសេនាធិការអោយនាយកដ្ឋាន និង ក្រសួងធ្វើការទាក់ទង និង សំរបសំរួលដោះស្រាយរាល់បញ្ហាកសិកម្មកម្ពុជា ជាមួយនឹងអគ្គនាយកដ្ឋានអាស៊ាននៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

- ប្រមូលផ្ដុំ និង លើកគំរោងអភិវឌ្ឍន៍គ្រប់ផ្នែកក្នុងវិស័យកសិកម្មសំរាប់អាស៊ាន ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង សំរេច ។
- សហការ និង សំរបសំរួលជាមួយអង្គភាពពាក់ព័ន្ធ អនុវត្តកិច្ចការអាស៊ាននៅក្នុងក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ អោយដំណើរការបានល្អស្របតាមកិច្ចការអភិវឌ្ឍន៍របស់ សមាគមអាស៊ាន ។

**មាត្រា ៣** : ក្របខ័ណ្ឌមន្ត្រីរាជការ របស់ការិយាល័យអាស៊ានកសិកម្ម អាស្រ័យដោយនាយកដ្ឋានផែនការ និង សហប្រតិបត្តិការកំណត់សំរេច ។

**មាត្រា ៤** : ការិយាល័យអាស៊ានកសិកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជំនួយការ ។

**មាត្រា ៥** : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ និង សហប្រតិបត្តិការ ព្រមទាំងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**តាវ សេងហួរ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦

## ប្រកាស លេខ : ៣៦០ ប្រក.កសក.ចន

## ស្ដីពីការរំសាយអង្គភាព

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ១៩៩៤ ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា